ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ ៧៥៦ / ២២ គ.ជ.ប.ជ.

# របាយការណ៍ខែកញ្ញា
# ស្ដីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅខែតុលា ឆ្នាំ២០២២

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះប្រទេសជាតិ បាន និងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តន៍ថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងការជះឥទ្ធិពលពីការប្រែប្រួលនៃសភាពការណ៍ពិភពលោក ដែលមានទាំងវិបត្តិសេដ្ឋកិច្ច សង្គ្រាមរុំារ៉ៃនៅបណ្ដាប្រទេសមួយចំនួន គ្រោះធម្មជាតិ(ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី ភ្លើងឆេះព្រៃ...) និងថែមទាំងគ្រោះមហន្តរាយដោយការរាតត្បាតដោយវីរុសកូវីដ-១៩ និងមេរោគបម្លែងថ្មី។

ក្រោយពីពិភពលោកកំពុងតែប្រយុទ្ធប្រឆាំងនឹងវិបត្តិជំងឺកូវីដ-១៩ មិនទាន់បានចប់ផង ក៏មានព្រឹត្តិការណ៍ថ្មីមួយទៀត ចាប់ពីខែ កុម្ភៈ ឆ្នាំ២០២២ មកដល់ពេលបច្ចុប្បន្ននេះមានការផ្ទុះសង្គ្រាមរវាងប្រទេស រុស្ស៊ី និងប្រទេសអុយក្រែន បានបង្កឱ្យមានវិបត្តិសេដ្ឋកិច្ចទូទាំងសកលលោក ដូចជាប្រេង និងឧស្ម័ន បានឡើងថ្លៃខ្ពស់ រហូតធ្វើឱ្យប្រទេសមួយចំនួនមានសេដ្ឋកិច្ចធ្លាក់ចុះយ៉ាងខ្លាំង និងមានវិបត្តិជំពាក់បំណុលគេដ៏ធ្ងន់ធ្ងរ ដែលមិនអាចដោះស្រាយបាន។

រាជរដ្ឋាភិបាលយើងបាន និងកំពុងតែ យកចិត្តទុកដាក់យ៉ាងខ្លាំង លើកិច្ចការពារអាយុជីវិតប្រជាពលរដ្ឋ ដែលបង្កដោយការរាតត្បាតដ៏ខ្លាំងក្លានៃវីរុសកូវីដ-១៩ និងផលប៉ះពាល់ដ៏ធំធេងលើ ជីវភាព និងសុខភាពប្រជាពលរដ្ឋ ព្រមទាំងសេដ្ឋកិច្ចសង្គមយ៉ាងធ្ងន់ធ្ងរ ជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ នូវផែនការសកម្មភាពនានា ដែលបានគ្រោងទុក និងត្រូវបន្ថែមភារកិច្ចក្នុងការដោះស្រាយ ទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ចំណែកឯប្រជាជនយើង មួយចំនួននៅតែមើលស្រាលស្ថានភាព មិនស្ដាប់ការអប់រំណែនាំ មិនតាមដានព័ត៌មានដែលមានប្រយោជន៍ តែបែរជាស្ដាប់ និងជឿការអូសទាញ ភូតភរពីមេខ្យល់ ធ្វើឲ្យពួកគាត់ធ្លាក់ទៅក្នុងអំពើជួញដូរមនុស្ស និងខាតបង់ទាំងទ្រព្យសម្បត្តិ និងកម្លាំងកាយ រហូតដល់ធ្លាក់ខ្លួនឈឺដ៏ធ្ងន់ធ្ងរថែមទៀត។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្ដៅ និងផ្ដល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្ដល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាព ជីវភាព និងផ្ដល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍

ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ-១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្ដល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្ដីព្រាងច្បាប់ ស្ដីពី"**ការពពោះជំនួស**"។
- ក្រសួងយុត្តិធម៌ ៖
  - រដ្ឋសភាបានអនុម័តច្បាប់ស្ដីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (MLA) (ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការណ៍ជាប្រញាប់ ដោយព្រះរាជក្រមលេខ នស/រកម ០៦២០/០២០ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០)។
  - បានរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

#### ក.២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បានកំពុងរៀបចំសេចក្ដីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្ដីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
  - បានកំពុងរៀបចំសេចក្ដីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្ដីពី "ការបញ្ជូនទណ្ឌិត"។

#### ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។

#### ក.៤. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្ដីព្រាងរៀបចំអនុក្រឹត្យ ស្ដីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

## ខ. ការបង្ការ ទប់ស្កាត់

### ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

#### ១.១.១. វេទិកាជាតិអន្តរសាសនា

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសហការជាមួយក្រសួង ស្ថាប័ន អង្គភាព និង អង្គការដៃគូពាក់ព័ន្ធ រៀបចំវេទិកាជាតិអន្តរសាសនា ប្រឆាំងការជួញដូរមនុស្ស លើកទី៦ ក្រោមប្រធានបទ «សូមកុំយកកម្ពុជា ធ្វើជាគោលដៅប្រព្រឹត្តអំពើជួញដូរមនុស្ស» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មានអ្នកចូលរួមសរុប ១.៣៥០នាក់ នៅអគារOCIC រាជធានីភ្នំពេញ។

#### ខ.១.២. ការអប់រំដោយផ្ទាល់

នៅក្នុងខែកញ្ញា ឆ្នាំ២០២២នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងប្រជាពលរដ្ឋ សរុបចំនួន ៩.៦៤៣លើក មានអ្នកចូលរួមសរុបចំនួន ៤១០.៧៩៥នាក់ (ធៀបនឹងខែសីហា មានចំនួន ៣២៥.៦៥៨នាក់ គឺមានការកើនឡើងចំនួន ៨៥.១៣៧នាក់ ស្មើនឹង២៦,១៤% ក្នុងនោះស្ត្រីចំនួន ២២២.២៦១នាក់។ ដូចមានតារាងលម្អិតខាងក្រោម៖

**តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ**

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ២៨ | ២.៨៦៧ | ២.០៩៥ | ១០១ | ៦.១៨៧ | ៣.០៧២ |
| | សរុប ក្រសួង ស្ថាប័ន | ២៨លើក | ២.៨៦៧នាក់ | ២.០៩៥នាក់ | ១០១លើក | ៦.១៨៧នាក់ | ៣.០៧២នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ៥ | ៧៦៦ | ៣៩៩ | ១.២១៧ | ៦២.២៥៤ | ៣២.៩៥៤ |
| ៣ | ខេត្តបាត់ដំបង | ៨៤២ | ៣៣.៣០៨ | ១៨.០៨៦ | ៦១៨ | ១៨.៤២៩ | ១០.០៥៨ |
| ៤ | ខេត្តពោធិ៍សាត់ | ៨២៦ | ៦០.៣២២ | ២៩.៥២៤ | ១៦៩ | ៦.៥៥៥ | ២.៨១៩ |
| ៥ | ខេត្តសៀមរាប | ២៧៦ | ១២.៧៧០ | ១០.០០៨ | ២៨ | ៧៨២ | ៥១៤ |
| ៦ | ខេត្តកំពង់ឆ្នាំង | ១.១១៥ | ២៥.៧៤៨ | ១៣.៣៨៤ | ៥៣៨ | ១១.២០៤ | ៥.៧៦៨ |
| ៧ | ខេត្តកំពង់ចាម | ១.៩៦៨ | ៩៨.៩៦៩ | ៥១.០៨៤ | ១.១២៤ | ៣៧.៣៧០ | ២០.៦២៥ |
| ៨ | ខេត្តព្រះសីហនុ | ២៤ | ១.៥៩២ | ២.៦៩១ | | | |
| ៩ | ខេត្តព្រះវិហារ | ១០ | ២.១៣៨ | ១.២៤៧ | | | |
| ១០ | ខេត្តស្វាយរៀង | | | | | | |
| ១១ | ខេត្តប៉ៃលិន | ៦១ | ៩៣៩ | ២៩០ | ៣៧ | ១.៤៥៨ | ៥៦៦ |
| ១២ | ខេត្តកោះកុង | | | | ៦០ | ១.៣៥៣ | ៧០៤ |
| ១៣ | ខេត្តកំពត | ៤ | ១៦៨ | ៨៤ | | | |
| ១៤ | ខេត្តកំពង់ធំ | ៤៥ | ២.៥៣២ | ២.១៧៤ | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៥ | ខេត្តតាកែវ | | | | | | |
| ១៦ | ខេត្តក្រចេះ | ១៧ | ៧៥៤ | ៥០៣ | | | |
| ១៧ | ខេត្តកែប | ២៤ | ៣.២៣១ | ១.៧៥៣ | ៥៥ | ២.៣៣៨ | ១.៤០៣ |
| ១៨ | ខេត្តកំពង់ស្ពឺ | | | | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | ៦ | ២.៩០៩ | ១.៦៨៨ | | | |
| ២១ | ខេត្តព្រៃវែង | ៤៣ | ៥.០៧៣ | ២.៣៦៨ | | | |
| ២២ | ខេត្តត្បូងឃ្មុំ | ៤ | ១.១១៨ | ៧៩៥ | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | ១ | ១២ | ៩ | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| សរុប រាជធានី-ខេត្ត | | ៥.២៧១លើក | ២៥២.៣៤៩នាក់ | ១៣៦.០៨៧នាក់ | ៤.២៤៣លើក | ១៤៩.៣៩២នាក់ | ៨១.០០៧នាក់ |
| សរុបរួម<br>ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន<br>៩.៦៤៣ លើក | | ចំនួនមនុស្សសរុប<br>៤១០.៧៩៥ នាក់ | | ចំនួនស្ត្រី<br>២២២.២៦១ នាក់ | |

### ១.១.៣. ការផ្សព្វផ្សាយរបស់អង្គការដៃគូ

| អង្គការ | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្ត្រី |
|---|---|---|---|
| អង្គការមូលនិធិអេ២១ (ខេត្តសៀមរាប) | ០៥ | ៧៥ | ៣៩ |
| អង្គការមូលនិធិអេ២១ (ខេត្តបន្ទាយមានជ័យ) | ០៧ | ១៨០ | ០ |
| អង្គការដំណក់ទឹក (ខេត្តបន្ទាយមានជ័យ) | ០២ | ១៥៨ | ៩៣ |
| សរុប | ១៤ លើក | ៤១៣ នាក់ | ១៣២ នាក់ |

### ខ.១.៤. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក

- ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ផ្សព្វផ្សាយតាមរយៈផេកហ្វេសប៊ុក មានអ្នកទស្សនាចំនួន ៣.៥៤៣នាក់។
- ខេត្តកំពង់ចាម៖ មន្ទីរពត៌មានខេត្ត ផ្សព្វផ្សាយតាមវិទ្យុ ១៥០លើក។
- ខេត្តសៀមរាប៖ មន្ទីរពត៌មានខេត្ត ផ្សព្វផ្សាយតាមវិទ្យុ ៥៤លើក។
- ខេត្តព្រៃវែង៖ មន្ទីរពត៌មានខេត្ត ផ្សព្វផ្សាយតាមវិទ្យុ ៥០លើក។

### ខ.១.៥. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ

- ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានចូលរួមបើកវគ្គបណ្តុះបណ្តាល និងជាគ្រូឧទ្ទេស ស្តីពី «**ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ**» ដល់សិក្ខាកាមជាកងអនុសេនាធំព្រលានយន្តហោះលេខ៧២៩ កងអនុសេនាធំកម្ទេចគ្រាប់មិនទាន់ផ្ទុះលេខ៨២៨ និងកងអនុសេនាធំកម្ទេចគ្រាប់មិនទាន់ផ្ទុះលេខ២៨៨ ដែលនឹងត្រូវចេញទៅបំពេញបេសកកម្មរក្សាសន្តិភាព អ.ស.ប នៅសាធារណរដ្ឋសូម៉ាលី។
- ខេត្តកំពង់ចាម៖ បានចូលរួមជាវាគ្មិនក្នុងវិទ្យុសរុប ០៨លើក៖(ស្នងការដ្ឋាននគរបាលខេត្ត ០២លើក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ០២លើក មន្ទីរកិច្ចការនារីខេត្ត ០៣លើក និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត ០១លើក)។
- ខេត្តសៀមរាប៖ រដ្ឋបាលស្រុកក្រឡាញ់ បានចូលរួមជាវាគ្មិនក្នុងវិទ្យុចំនួន ០១លើក។

**ខ.២. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)**

- ខេត្តសៀមរាបៈ ចែកខិត្តប័ណ្ណផ្សព្វផ្សាយ ចំនួន ៣៥០ច្បាប់។
- អង្គការសាម៉ារីតាន់ភឺស (ខេត្តបន្ទាយមានជ័យ)៖ ចែកខិត្តប័ណ្ណផ្សព្វផ្សាយ ចំនួន ៤០៤ច្បាប់។
- អង្គការសាម៉ារីតាន់ភឺស (ខេត្តបាត់ដំបង)៖ ចែកខិត្តប័ណ្ណផ្សព្វផ្សាយ ចំនួន ៩៩១ច្បាប់។

**ខ.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ**

- កំពង់ឆ្នាំង៖ ស្នងការដ្ឋាននគរបាលខេត្ត បានចុះត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់សិប្បកម្មឡឥដ្ឋ ចំនួន ១៣កន្លែង នៅស្រុករលាប្អៀរ ស្រុកកំពង់ត្រឡាច និងក្រុងកំពង់ឆ្នាំង មានកម្មករ ៣១០នាក់ (ស្រី ១០០នាក់) (ពុំមានបទល្មើសជួញដូរទេ)។
- ខេត្តសៀមរាបៈ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះអធិការកិច្ចជនបរទេស ចំនួន ៦៧សហគ្រាស ពិនិត្យឃើញមានជនបរទេសចំនួន ១៦៨នាក់ (ស្រី ៤៩នាក់) ក្នុងនោះអ្នកមានប័ណ្ណ និងសៀវភៅការងារចំនួន ១៤៧នាក់ (ស្រី ៤១នាក់) និងគ្មានប័ណ្ណនិងសៀវភៅការងារ ចំនួន ២១នាក់ (ស្រី ០៨នាក់)។

**ខ.៣.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក**

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុក ទៅក្រៅប្រទេសទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទងសរុបចំនួន ១៣៩.១៨២នាក់ (ស្រី ៦០.៦១៣នាក់) អនីតិជន ១.២៤៤នាក់ (ស្រី ៤២៨នាក់)៖
  - ស្របច្បាប់ ចំនួន ១០៤.៨៦៤នាក់ (ស្រី ៤៦.៦៨១នាក់) អនីតិជន ៣១៦នាក់(ស្រី១០២នាក់)
  - មិនស្របច្បាប់ចំនួន ៣៣.៦៨៥នាក់ (ស្រី ១៣.៦៤៧នាក់) អនីតិជន ៨២៤នាក់(ស្រី ២៩៧នាក់)
  - ដាច់ការទាក់ទងចំនួន ៦៣៣នាក់ (ស្រី ២៨៥នាក់) អនីតិជន ១០៤នាក់(ស្រី ២៩)។
- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុក ត្រឡប់មកវិញដោយខ្លួនឯង ពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន ៧៤.៣៩៣នាក់ (ស្រី ៣៧.៦២៧នាក់) អនីតិជន ៣៩៧នាក់ (ស្រី ១៦០នាក់)។

**ខ.៣.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ**

- អគ្គស្នងការដ្ឋាននគរបាលជាតិ
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលក្រចេះ តាកែវ កែប កំពង់ឆ្នាំង និងខេត្តសៀមរាប បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម ដល់ម្ចាស់អាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា បានចំនួន ១៨០គោលដៅ មនុស្សចំនួន ៦៩៨នាក់ (ស្រី ៣៨៨នាក់)។
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង ក្រចេះ បាត់ដំបង តាកែវ កំពត កោះកុង ព្រះវិហារ និងខេត្តបន្ទាយមានជ័យ បានល្បាតឃ្លាំមើលគោលដៅសង្ស័យ មានសកម្មភាពអាជីវកម្មផ្លូវភេទ ចំនួន ២៣លើក។

**ខ.៣.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

- ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំចុះបញ្ជីការរៀបអាពាហ៍ពិពាហ៍ ចំនួន ១៦៨នាក់ (ស្រី ២២នាក់) មាន ១៦សញ្ជាតិ ក្នុងនោះជនជាតិកូរ៉េខាងត្បូង ៥៤នាក់(ស្រី ១០នាក់) ចិន ៥១នាក់(ស្រី ០១នាក់) អាមេរិក ៣២នាក់(ស្រី ០៧នាក់) បារាំង ១១នាក់ កាណាដា ០៤នាក់(ស្រី

០១នាក់) ម៉ាឡេស៊ី ០៣នាក់ ជប៉ុន ០៣នាក់(ស្រី ០១នាក់) អាឡឺម៉ង់ ០២នាក់ ថៃ ០១នាក់ នេប៉ាល់ ០១នាក់ វៀតណាម ០១នាក់ សិង្ហបុរី ០១នាក់ អូស្ត្រាលី ០១នាក់(ស្រី) ឥណ្ឌា ០១នាក់ រុស្សី ០១នាក់(ស្រី) និងស៊ុយអែត ០១នាក់ និងវាយតំលៃបញ្ជូនឱ្យក្រុមការងារច្រកចេញចូលតែមួយបានចំនួន ១៤២នាក់។ បានប្រមូលព័ត៌មានពីការសួរសុខទុក្ខនារីខ្មែរ រៀបការទៅរស់នៅប្រទេសកូរ៉េខាងត្បូងចំនួន ០៧នាក់ (ស្រី ០៥នាក់)។

### ខ.៤. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

- ខេត្តព្រះសីហនុ៖ បន្តសហការជាមួយអង្គការម្លប់តាប៉ាង ធ្វើការទំនាក់ទំនងជាប្រចាំជាមួយបណ្តាញម៉ូតូឌុប ក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ ភ្នាក់ងារទេសចរណ៍ និងសហគមន៍ចំនួន ១.១៣៣នាក់ ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្រ្កាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

#### គ.១.១. ការងារបង្រ្កាប និងសង្រ្គោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ១៨ករណី(ធៀបនឹងខែសីហា មានចំនួន ១៥ករណី កើនឡើងចំនួន ០៣ករណី) ស្មើនឹង២០% ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ២៥នាក់ (ស្រី ០៤នាក់) ក្នុងនោះជនសង្ស័យជាអនីតិជន ០៤នាក់ និងជាជនជាតិចិន ០៤នាក់។

សង្រ្គោះជនរងគ្រោះ ចំនួន ៤១នាក់ មាន: អាយុក្រោម១៥ឆ្នាំ ១៩នាក់ អាយុ១៥-១៧ឆ្នាំ ០៦នាក់ និងអាយុ១៨ឆ្នាំឡើង ១៦នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ០៣នាក់ និងគ្រួសារ ៣៨នាក់) ក្នុងនោះចែកជា៖

១. ករណីអំពើជួញដូរមនុស្ស

បង្រ្កាបបាន ០១ករណី/០២ករណី (ថយចុះ ០១ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០២នាក់ ជនសង្ស័យជាជនជាតិចិន ០២នាក់។ សង្រ្គោះជនរងគ្រោះចំនួន ០១នាក់ មាន: អាយុ១៨ឆ្នាំឡើង ០១នាក់ (ប្រគល់ឱ្យគ្រួសារ ០១នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -អំពើលក់ដូរមនុស្ស | ០១ | ០១ | ០២ | ចិន២ |
| *សរុប* | *០១ ករណី* | *០១ នាក់* | *០២ នាក់* | *០២ នាក់* |

២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្រ្កាបបាន ១៧ករណី/១៣ករណី (កើនឡើង ០៤ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ២៣នាក់ (ស្រី ០៤នាក់) ជនសង្ស័យជាអនីតិជន ០៤នាក់ និងជនជាតិចិន ០២នាក់។ សង្រ្គោះជនរងគ្រោះចំនួន ៤០នាក់ មាន: អាយុក្រោម១៥ឆ្នាំ ១៩នាក់ និងអាយុ១៥-១៧ឆ្នាំ ០៦នាក់ និងអាយុ១៨ឆ្នាំឡើង ១៥នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ០៣នាក់ និងគ្រួសារ ៣៧នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -សញ្ជារកម្ម(មានអនីតិជន) | ០១ | ០៧ | ០៣ | |
| -ស្ថានទម្ងន់ទោសនៃសញ្ជារកម្ម | ០១ | ១០ | ០២ | ចិន២ |
| -សញ្ជារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០១ | ០៣ | ០២ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ១១ | ១៧ | ១៣ (អ.នី០៤) | |
| -អំពើអាសអាភាសនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៣ | ០៣ | ០៣ | |
| *សរុប* | *១៧ ករណី* | *៤០ នាក់* | *២៣ នាក់* | *០២ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- អគ្គស្នងការដ្ឋាននគរបាលជាតិ
  - នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួល និងសម្ភាសន៍ជនរងគ្រោះ ដែលបានវិលត្រឡប់មកពីក្រៅប្រទេស ចំនួន ២២នាក់(ស្រី ២០នាក់) អនីតិជន ០១នាក់(ស្រី) មកពីប្រទេសចិន ២០នាក់(ស្រី) អនីតិជន ០១នាក់(ស្រី) និងម៉ាឡេស៊ី ០២នាក់។ ជាលទ្ធផល រងគ្រោះដោយអាពាហ៍ពិពាហ៍ផ្ទុយពីធម្មៈទៅចិន ២០នាក់(ស្រី) អនីតិជន ០១នាក់ និងស្នាក់នៅ ដោយខុសច្បាប់ ប្រទេសម៉ាឡេស៊ី ០២នាក់។
  - ខេត្តបន្ទាយមានជ័យៈ ស្នងការនគរបាលខេត្ត ពលករចូលតាមច្រកអូរបីជាន់ ច្រកបឹងត្រកួន ច្រកចំបក់ និងច្រកអន្តរជាតិប៉ោយប៉ែត ចំនួន ៦០លើក មនុស្សចំនួន ២.៧៨៥នាក់ (ស្រី ១.១៤៦នាក់) អនីតិជន ៣១៨នាក់។
  - ខេត្តកោះកុងៈ បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសថៃបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ០២លើក មនុស្សចំនួន ០២នាក់(ស្រី)។
  - ខេត្តស្វាយរៀងៈ បានទទួលពលរដ្ឋខ្មែរ ដែលឆ្លងដែនខុសច្បាប់ ទៅធ្វើការនៅប្រទេសវៀតណាម ចំនួន ០១លើក មនុស្សចំនួន ០៩នាក់ (ស្រី ០៦នាក់ អនីតិជន ០៣នាក់)។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការងារបណ្តុះបណ្តាល

| សកម្មភាពរៀបចំវគ្គបណ្ដុះបណ្ដាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានបើក វគ្គបណ្ដុះបណ្ដាល ស្ដីពី «**ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ**» ដល់សិក្ខាកាមជាកងអនុសេនាធំព្រលានយន្តហោះលេខ៧២៩ កងអនុសេនាធំកម្ទេចគ្រាប់មិនទាន់ផ្ទុះលេខ៨២៨ និងកងអនុសេនាធំកម្ទេចគ្រាប់ | ០១ | ១០៦ | ១៦ |

| | | | |
|---|---|---|---|
| មិនទាន់ផ្ទះលេខ២៨៨ ដែលនឹងត្រូវចេញទៅបំពេញបេសកកម្មរក្សាសន្តិភាព អ.ស.ប នៅសាធារណរដ្ឋសូម៉ាលី។ | | | |
| **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន៖**<br>- បានសហការជាមួយអង្គការសកម្មភាពដើម្បីកុមារ បើកវគ្គបណ្តុះបណ្តាល ស្តីពីការកេងប្រវ័ញ្ច ផ្លូវភេទតាមប្រព័ន្ធអនឡាញ យន្តការណ៍ទាក់ទងនឹងរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ និងការស៊ើបអង្កេតបទល្មើសផ្លូវភេទបែបកុមាររមេត្រី។<br>- បានសហការជាមួយស្ថានទូតបារាំង បើកវគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងបទល្មើសផ្សព្វផ្សាយរូបភាពរបស់កុមារលើប្រព័ន្ធអ៊ីនធ័រណេត និងទេសចរណ៍ផ្លូវភេទ។<br>- បានសហការជាមួយការិយាល័យស៊ើបអង្កេតថ្នាក់សហពន្ធ័(FBI) បើកបណ្តុះបណ្តា ស្តីពីការស៊ើបអង្កេតលើអំពើកេងប្រវ័ញ្ចកុមារ។ | ០១<br><br>០១<br><br>០១ | ៥៥<br><br>២០<br><br>២០ | ១៣<br><br>០៣<br><br>០៣ |
| **ខេត្តកំពង់ឆ្នាំង៖**<br>- បានសហការជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី បើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ការគ្រប់គ្រងករណី។<br>- មន្ទីរកិច្ចការនារីខេត្ត បានសហការជាមួយសមាគមន៍ភ្នំនាងកង្រី បើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុក និងអំពើជួញដូរមនុស្ស។ | ០១<br><br>០១ | ២៥<br><br>១៧ | <br><br>០៩ |
| - **ខេត្តព្រះវិហារ៖** ស្នងការដ្ឋាននគរបាលខេត្ត បានសហការជាមួយអង្គការ អាដ្រា បើកវគ្គបណ្តុះបណ្តាល ស្តីពីការផ្តល់ប្រឹក្សាយោបល់ពាក់ព័ន្ធនឹងអំពើ ហិង្សា និងការរំលោភបំពានគ្រប់ទម្រង់។ | ០១ | ៤៨ | ០៥ |
| - **ខេត្តស្វាយរៀង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយក្រុមហ៊ុនចំនួន៣ បើកវគ្គបណ្តុះបណ្តាល ដោយបានបញ្ជ្រាបការយល់ដឹងអំពីចំណាកស្រុកប្រកបដោយសុវត្ថិភាព រួមបញ្ចូលជាមួយនូវប្រធានបទស្តីពីបំនិនជីវិត អាហារូបត្ថម្ភ គ្រឿងញៀន និងសុវត្ថិភាពចរាចរណ៍ ការគ្រប់គ្រងសារជាតុគីមី។ | ០៣ | ៥៣ | ៣៩ |
| **សរុប** | **១០ វគ្គ** | **៣៨៤ នាក់** | **៨៨ នាក់** |

## ក.២. សិក្ខាសាលា

- **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖**
  - បានសហការ ឧបត្ថម្ភគាំទ្រជាមួយអង្គការ IOM ( UN MIGRATION) បើកសិក្ខាសាលា ស្តីពីការបង្កើតនីតិវិធីបទដ្ឋាន នៃយន្តការបញ្ជូនថ្នាក់ជាតិ សម្រាប់ជនរងគ្រោះដោយអំពើរជួញដូមនុស្ស និងជនទេសន្តរប្រវេសន៍ ដែលងាយរងគ្រោះ មានសិក្ខាកាមចូលរួមសរុប ៤០នាក់។
  - សហការរៀបចំដោយអង្គការអាស៊ានអាក់ បើកសិក្ខាសាលា ស្តីពីការយកចិត្តទុកដាក់ លើជនរងគ្រោះ និងសំណុំទិន្នន័យ ពីការប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងឯកឧត្តម Will Nankervis ឯកអគ្គរដ្ឋទូតអូស្ត្រាលី ប្រចាំនៅកម្ពុជា មានការចូលរួម លោកស្រី Lucia Pietropaoli ប្រធាន ASIAN ACT ថ្នាក់តំបន់ ក្រសួងយុត្តិធម៌ ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តំណាងពីស្ថាប័នយុត្តិធម៌ ចៅក្រម ព្រះរាជអាជ្ញា ខេត្តព្រះសីហនុ សៀមរាប រាជធានីភ្នំពេញ និងអង្គការដៃគូ សរុបសិក្ខាកាមចំនួន ៥៣នាក់ (ស្រី ១៨នាក់) នៅសណ្ឋាគារកាំបូឌីយ៉ាណា។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. ក្នុងប្រជុំក្នុងប្រទេស និងក្រៅប្រទេស

- អគ្គលេខាធិកាដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បាន អញ្ជើញ៖

- ដឹកនាំកិច្ចប្រជុំផ្ទៃក្នុងពិភាក្សា ស្តីពីការរៀបចំរបាយការណ៍ប្រចាំខែ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។
- បើកកិច្ចប្រជុំ យុត្តិធម៌ព្រហ្មទណ្ឌ ស្តីពីនីតិវិធីពាក់ព័ន្ធនឹងបទល្មើសជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សមាសភាពចូលរួមមាន ប្រធានសាលាដំបូងខេត្ត ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្ត អគ្គលេខាធិការរង គ.ជ.ប.ជ ព្រះរាជអាជ្ញារង ចៅក្រម ថ្នាក់ដឹកនាំមន្ទីរអង្គភាពនានាជុំវិញខេត្ត គណៈអភិបាលក្រុង ស្រុក អធិការ កងរាជអាវុធហត្ថ ក្រុង-ស្រុក នាយប៉ុស្តិ៍ឃុំ-សង្កាត់ និង អង្គការដៃគូជាតិ និងអន្តរជាតិ សរុបចំនួន ១០១នាក់ (ស្រី ៣៧នាក់) នៅខេត្តសៀមរាប។
- ដឹកនាំកិច្ចប្រជុំគណៈកម្មការ ត្រៀមរៀបចំវេទិកាអន្តរសាសនា សហការជាមួយគណៈកម្មាធិការរៀបចំបុណ្យជាតិ។
- ដឹកនាំកិច្ចប្រជុំផ្ទៃក្នុងដកពិសោធន៍ការងាររបស់ថ្នាក់ដឹកនាំ និងមន្ត្រី អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោយបញ្ចប់កម្មវិធីអន្តរសាសនា លើកទី៦ អ្នកចូលរួមចំនួន ៣៤នាក់ (ស្រី ០៦នាក់) នៅសាលប្រជុំ គ.ជ.ប.ជ។

លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត ប៉ុណ្ណ **សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញ៖

- ដឹកនាំកិច្ចប្រជុំរបស់ក្រុមការងារផ្សព្វផ្សាយអប់រំ នៃក្រុមការងារចាត់តាំង អនុវត្តផែនការប្រតិបត្តិការ បង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរកម្លាំងពលកម្ម និងអាជីវកម្មផ្លូវភេទ នៅកម្ពុជា នៅសាលប្រជុំ គ.ជ.ប.ជ។
- ដឹកនាំកិច្ចប្រជុំក្រុមការងារពិនិត្យបទបង្ហាញតំបន់ ស្តីពីសិទ្ធមនុស្ស និងការប្រឆាំងការជួញដូរមនុស្ស ក្នុងតំបន់អាស៊ាន និងពិនិត្យរបាយការណ៍ ក្រុមការងារផ្សព្វផ្សាយអប់រំ នៃគណៈបញ្ជាការដឹកនាំ ប្រតិបត្តិ នៅសាលប្រជុំ គ.ជ.ប.ជ។
- ដឹកនាំកិច្ចប្រជុំក្រុមការងារផ្សព្វផ្សាយអប់រំ ក្នុងគោលបំណងផ្សព្វផ្សាយសមាសភាព និងផែនការ របស់ក្រុមការងារផ្សព្វផ្សាយអប់រំ ពិភាក្សាអំពីបញ្ហាប្រឈម និងយន្តការសម្រាប់អនុវត្តផែនការឱ្យ កាន់តែមានប្រសិទ្ធភាព អ្នកចូលរួមចំនួន ១៣នាក់ (ស្រី ០២នាក់) នៅសាលប្រជុំ គ.ជ.ប.ជ។

## គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ៤៣លើក មានអ្នកចូលរួមសរុប ៥៣០នាក់ (ស្រី ១៨៥នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ២៤លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត ចំនួន ១៩លើក។(**ឧបសម្ព័ន្ធ១**)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការផ្ញើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

### គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

### ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែតុលា ឆ្នាំ ២០២២

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាព ជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.................ខែ..........ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី..២៥..ខែ..វិច្ឆិកា..ឆ្នាំ២០២២

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

- ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
- សមាជិកក្រុមការងារគ.ជ.ប.ជ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៤៣លើក) មនុស្សចំនួន ៣០០នាក់ (ស្រី ១២៨នាក់)

<table>
<tr><th>ស្ថាប័ន<br>សម្របសម្រួល</th><th>សកម្មភាព</th></tr>
<tr><td>គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស<br>(គ.ជ.ប.ជ)</td><td>▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ<br>- បានអញ្ជើញជាអធិបតីក្នុងសិក្ខាសាលា ស្តីពីលទ្ធផលស្រាវជ្រាវ «ពលករទេសន្តរប្រវេសន៍តាមរដូវកាល»របស់ក្រុមអ្នកស្រាវជ្រាវក្រោមគម្រោង ASIA CTIP តាមរយៈជំនួយឧបត្ថម្ភពីមូលនីធិ USAID ខេត្តសៀមរាប។<br>- បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំ ត្រួតពិនិត្យការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរកម្លាំងពលកម្ម និងអាជីវកម្មផ្លូវភេទ នៅខេត្តព្រះសីហនុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។<br>- បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំណែនាំ អំពីវិធានការប្រឆាំងការអំពើជួញដូរមនុស្ស ជួញដូរកម្លាំងពលកម្ម និងអាជីវកម្មផ្លូវភេទ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។<br>- បានដឹកនាំក្រុមការងារ របស់អគ្គលេខាធិការដ្ឋាន គ ជ.ប.ជ.ចុះត្រួតពិនិត្យវឌ្ឍន៍ភាព ការងាររៀបចំប្រារព្ធពិធីវេទិកាអន្តរសាសនា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៊ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ<br>- បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំតាមប្រព័ន្ធវីដេអូ ស្តីពី "ការប្រឹក្សាសិទ្ធិមនុស្ស របស់គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ាន ទទួលបន្ទុកសិទ្ធិមនុស្ស (AICHR) និងប្រឆាំងការជួញដូរមនុស្សក្នុងតំបន់អាស៊ាន" ដែលបានរៀបចំឡើងរយៈពេល២ថ្ងៃ នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី។<br>- បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមការងារផ្សព្វផ្សាយអប់រំ ក្នុងគោលបំណងផ្សព្វផ្សាយសមាសភាព និងផែនការរបស់ក្រុមការងារផ្សព្វផ្សាយអប់រំ ព្រមទាំងពិភាក្សាអំពីបញ្ហាប្រឈម និងយន្តការសម្រាប់អនុវត្តផែនការឱ្យកាន់តែមានប្រសិទ្ធភាព នៅសាលប្រជុំសាលាខេត្តព្រះសីហនុ។<br>▪ លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ៣៩ច្បាប់ លិខិតចូល ២៦ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ២៤ច្បាប់ លិខិតចូល ២៦ច្បាប់។</td></tr>
</table>

| | |
|---|---|
| | - រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រៀងរាល់កិច្ចប្រជុំ។<br>- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែកញ្ញា ឆ្នាំ២០២២ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បូកសរុបរបាយការណ៍ប្រចាំខែកញ្ញា ឆ្នាំ២០២២ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។<br>- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាគារវីគី។<br>- គ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។<br>- គ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអគ្គលេខាធិការ គជ.ប.ជ.។<br>- ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ wiki ncct convert ជាPDF បានចំនួន១៦៦ច្បាប់ និងបានចងក្រងជាសៀវភៅជាក់ជូនលោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងជូនលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ។<br>- អាប់ឡូតរូបភាពសកម្មភាព គ.ជ.ប.ជ និង គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធ Wiki បានចំនួន២៦សកម្មភាព។<br>- អាប់ឡូតឯកសារចូលបណ្ណាល័យវីគីបានចំនួន ២២ច្បាប់។<br>▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**<br>- ឯកឧត្តម អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួម<br>○ កិច្ចប្រជុំរបស់ក្រុមការងារផ្សព្វផ្សាយអប់រំ នៃក្រុមការងារចាត់តាំងអនុវត្តផែនការប្រតិបត្តិការ បង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរកម្លាំងពលកម្ម និងអាជីវកម្មផ្លូវភេទ ក្រោមអធិបតីភាព លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។<br>○ កិច្ចប្រជុំក្រុមការងារពិនិត្យបទបង្ហាញតំបន់ ស្តីពីសិទ្ធមនុស្ស និងការប្រឆាំងការជួញដូរមនុស្ស ក្នុងតំបន់អាស៊ាន និងពិនិត្យរបាយការណ៍ក្រុមការងារផ្សព្វផ្សាយអប់រំ នៃគណៈបញ្ជាការដឹកនាំប្រតិបត្តិ ក្រោមអធិបតីភាព លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។<br>○ កិច្ចប្រជុំក្រុមការងារផ្សព្វផ្សាយអប់រំ ក្នុងគោលបំណងផ្សព្វផ្សាយសមាសភាព និងផែនការរបស់ក្រុមការងារផ្សព្វផ្សាយអប់រំ ពិភាក្សាអំពីបញ្ហាប្រឈម និងយន្តការសម្រាប់អនុវត្តផែនការឱ្យកាន់តែមានប្រសិទ្ធភាព ក្រោមអធិបតីភាព លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។ |

- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**
  - លោកប្រធានក្រុមជំនួយកិច្ចការ បានចូលរួមកិច្ចប្រជុំ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ ដើម្បីរៀបគំរោងការធ្វើសិក្ខាសាលា អំពីការបញ្ចប់សេចក្តីព្រាងគោលនយោបាយជាតិ រៀបចំឡើងដោយនាយកដ្ឋានមន្ទីរពេទ្យ នៅសណ្ឋាគារ អង្គរប៉ាវ៉ាឌី ខេត្តសៀមរាប។
  - ឯកឧត្តម អគ្គលេខាធិការរង គ.ជ.ប.ជ និងលោកប្រធានក្រុមជំនួយកិច្ចការ បានចូលរួមបើកសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ បញ្ចប់សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ ឆ្នាំ២០២២ ដល់ឆ្នាំ២០៣០ នៅសណ្ឋាគារ អង្គរប៉ាវ៉ាឌី ខេត្តសៀមរាប។
  - លោកអនុប្រធានក្រុមជំនួយកិច្ចការ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីលិខិតបទដ្ឋានអន្តរជាតិ ពាក់ព័ន្ធស្មុំកូន និងកុមារដែលមិនមានអ្នកមើលថៃ នៅសាលប្រជុំ Kampus រាជធានីភ្នំពេញ។
  - ឯកឧត្តម អគ្គលេខាធិការរង គ.ជ.ប.ជ និងលោកប្រធានក្រុមជំនួយកិច្ចការ បានចូលរួមសម្របសម្រួលវគ្គបណ្តុះបណ្តាល ដល់មន្ត្រីនគរបាល និងប្រជាការពារ ស្តីពីការផ្តល់ប្រឹក្សាពាក់ព័ន្ធ និងអំពើហិង្សា ការរំលោភបំពានគ្រប់ទំរង់ ខេត្តព្រះវិហារ។
  - ឯកឧត្តម អគ្គលេខាធិការរង គ.ជ.ប.ជ និងលោកប្រធានក្រុមជំនួយកិច្ចការ បានចូលរួមកម្មវិធីផ្សព្វផ្សាយរបាយការណ៍ នៃការសិក្សាស្រាវជ្រាវ Disrupting Harm Study ស្តីពីការបញ្ឈប់គ្រោះថ្នាក់ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញ នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។
- **ក្រុមជំនួយកិច្ចការយុត្តិធម៌**
  - ឯកឧត្តម អគ្គលេខាធិការរង គ.ជ.ប.ជ និងលោកប្រធានក្រុមជំនួយកិច្ចការ បានចូលរួមក្នុងកិច្ចប្រជុំតាមប្រព័ន្ធវីដេអូ ស្តីពី "**ការប្រឹក្សាសិទ្ធិមនុស្ស របស់គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ាន ទទួលបន្ទុកសិទ្ធិមនុស្ស (AICHR)និងការប្រឆាំងការជួញដូរមនុស្សក្នុងតំបន់អាស៊ាន**" ដែលបានរៀបចំឡើងរយៈពេល២ថ្ងៃ នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី។
  - ឯកឧត្តម អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួមកិច្ចប្រជុំ SOMTC រយៈពេល០៣ថ្ងៃតាមប្រព័ន្ធវីដេអូ ៖
    - ប្រជុំត្រៀមសម្រាប់រៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន លើកទី១៦ និងកិច្ចប្រជុំពាក់ព័ន្ធ ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ោ ភក្តិ** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ។
    - ប្រជុំស្តីពីកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន លើកទី១៦ និងកិច្ចប្រជុំពាក់ព័ន្ធ រួមទាំងពិធីផ្ទេរដំណែងប្រធានពីកម្ពុជា ជូនឥណ្ឌូណេស៊ី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន AMMTC-កម្ពុជា។
    - ប្រជុំស្តីពីកិច្ចប្រជុំពិគ្រោះយោបល់AMMTC+៣ លើកទី១២ ក្រោមអធិបតីភាព ឯកឧត្តម **ងី ច័ន្ទផល** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ។

| | |
|---|---|
| | ▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**<br>- លោកជំទាវ អគ្គលេខាធិការរង គ.ជ.ប.ជ និងលោកប្រធានក្រុមជំនួយកិច្ចការ បានចូលរួមធ្វើជាគ្រូឧទ្ទេស ក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងការស្វែងយល់អំពីជួញដូរមនុស្ស និងការរំលោកបំពាននានា នៅខេត្តបាត់ដំបង។<br>- លោកជំទាវ អគ្គលេខាធិការរង គ.ជ.ប.ជ និងលោកប្រធានក្រុមជំនួយកិច្ចការ បានចូលរួមក្នុងកិច្ចប្រជុំតាមប្រព័ន្ធវីដេអូ ស្តីពីការប្រឹក្សាសិទ្ធិមនុស្ស របស់គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ាន ទទួលបន្ទុកសិទ្ធិមនុស្ស (AIChR) និងការប្រឆាំងការជួញដូរមនុស្ស ក្នុងតំបន់អាស៊ាន ដែលបានរៀបចំឡើងរយៈពេល២ថ្ងៃ នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី។<br>▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**<br>- ឯកឧត្តម អគ្គលេខាធិការរង គ.ជ.ប.ជ និងលោកប្រធានក្រុមជំនួយកិច្ចការ បានចូលរួមសិក្ខាសាលា ស្តីពីសំណុំទិន្នន័យ ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស សហការរៀបចំដោយ គ.ជ.ប.ជ និងកម្មវិធីអាស៊ានអូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស នៅសណ្ឋាគារកាំបូឌីយ៉ាណា។<br>▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់**<br>- ឯកឧត្តម អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួមកិច្ចប្រជុំយុត្តិធម៌ព្រហ្មទណ្ឌ ស្តីពីនីតិវិធីពាក់ព័ន្ធនឹងបទល្មើសជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៅខេត្តសៀមរាប<br>- លោកប្រធានក្រុមជំនួយកិច្ចការ បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយផែនការ ស្តីពីការចាត់តាំងអនុវត្តផែនការប្រតិបត្តិការ បង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ នៅសាលប្រជុំអគ្គស្នងការដ្ឋាននគរបាលជាតិ។<br>- លោកប្រធានក្រុមជំនួយកិច្ចការ បានចូលរួមសិក្ខាសាលា ស្តីពីតុលាការដែលយកចិត្តទុកដាក់ជនរងគ្រោះ និងសំណុំទិន្នន័យអំពើជួញដូរមនុស្ស នៅសណ្ឋាគារកាំបូឌីយ៉ាណា។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ១៩លើក អ្នកចូលរួមសរុបចំនួន ៥៣០នាក់ (ស្រី ១៨៥នាក់)** | |
| ខេត្តសៀមរាប | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំយុត្តិធម៌ព្រហ្មទណ្ឌ ស្តីពីនីតិវិធីពាក់ព័ន្ធនឹងបទល្មើសជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ អ្នកចូលរួមចំនួ១០២នាក់ ស្រី៣៧នាក់។<br>- ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំកិច្ចប្រជុំចំនួន០៦លើក អ្នកចូលរួមចំនួន១៥៩នាក់ ស្រី៥៣នាក់។ |
| ខេត្តកណ្តាល | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានបើកកិច្ចប្រជុំបូកសរុបលទ្ធការងារប្រចាំខែកញ្ញា ត្រីមាសទី៣ និងលើកទិសដៅបន្ត ឆ្នាំ២០២២ អ្នកចូលរួមចំនួន៦៤នាក់ ស្រី២៩នាក់។ RPTFL |

| | |
|---|---|
| | - ក្រុមការងារក្រុង-ស្រុក បានរៀបចំប្រជុំប្រចាំខែ បានចំនួន ០៧លើក អ្នកចូលរួមចំនួន២០៥នាក់ ស្រី៩៥នាក់។ |
| ខេត្តកោះកុង | លេខាធិការដ្ឋាន គ.ខ.ប.ជ៖<br>- បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយផែនការ ស្តីពីការចាត់តាំងផែនការ ការប្រតិបត្តិបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ។<br>- បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ ពាក់ព័ន្ធនឹងការត្រួតពិនិត្យជនបរទេស ការស៊ើបអង្កេត និងស្រាវជ្រាវបណ្តាញ នាំមនុស្សឆ្លងដែនខុសច្បាប់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ។ |
| ខេត្តបន្ទាយមានជ័យ | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយផែនការប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ។ |
| ខេត្តកំពង់ឆ្នាំង | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធការងារប្រចាំខែកញ្ញា ឆ្នាំ២០២២។ |